# "ត្រចៀកធំ" និង "ប្រមុះធំ"

នៅសម័យបុរាណ ខ្មែរទទួលឥទ្ធិពលអារ្យធម៌ឥណ្ឌា ដែលនាំឱ្យមានសាសនាធំៗពីរបានចាក់សយ៉ាងរឹងមាំក្នុងសង្គមនាពេលនោះ ពោល គឺព្រហ្មញ្ញសាសនា និងព្រះពុទ្ធសាសនា។ វត្តមានព្រហ្មញ្ញសាសនានៅក្នុងសង្គមខ្មែរ បានញុាំងឱ្យខ្មែរចេះកសាងសំណង់ប្រាសាទផ្សេងៗដែលលាយឡំនូវក្បាច់ចម្លាក់រូបទេពនិករ ចម្លាក់សត្វទេវកថាផ្សេងៗ។ល។ សម្រាប់ប្រណិប័តន៍ចំពោះសាសនានេះ។ រូបចម្លាក់ទេព និងចម្លាក់សត្វផ្សេងៗ គេនិយមធ្វើអំពីថ្មដែលអាចនៅរក្សារូបរាងដើមច្រើនសម័យកាលបន្តបន្ទាប់។ ប៉ុន្តែ សម័យក្រោយមកទៀត នៅពេលដែលអ្នកស្រុកប្រទះឃើញរូបទាំងនោះ អ្នកខ្លះក៏ស្គាល់ រីអ្នកខ្លះទៀតក៏ពុំស្គាល់ថាជារូបទេពអ្វី ឬសត្វទេវកថាអ្វីឡើយ។ ម្ល៉ោះហើយ ការហៅឈ្មោះសម្គាល់រូបទេព ឬរូបសត្វទាំងនោះក៏បានប្តូរទៅតាមរបៀបថ្មីមួយ តាមការប្រទះភ្នែកផ្ទាល់របស់អ្នកស្រុក។ នៅក្នុងអត្ថបទខ្លីនេះ យើងនឹងបង្ហាញរូបចម្លាក់សម័យបុរាណចំនួនពីរដែលអ្នកស្រុកសម័យក្រោយហៅថា "ត្រចៀកធំ" និង "ប្រមុះធំ"។

រូបភាពទី១ គឺជាបដិមាព្រះគណេសមានព្រះហស្តប្រាំបីមួយអង្គ តម្កល់នៅលើលានមួយនៅតំបន់ភ្នំគូលែនដែលអ្នកស្រុកហៅឈ្មោះថា "**តាត្រចៀកធំ**" ឬហៅតាមឯកសារចាស់ថា "**តាត្រចៀកវែង**"[១] ស្ថិតនៅភូមិត្រពាំងទឹម ឃុំតាសៀម ស្រុកស្វាយលើ ខេត្តសៀមរាប (រូបលេខ១)។ បដិមាព្រះគណេសនេះ មានកម្ពស់១.៩៥ម៉ែត្រ ទទឹង១.៥ម៉ែត្រ កម្រាស់០.៣ម៉ែត្រ ហើយមានលក្ខណៈស្រដៀងរូបព្រះគណេសនៅពើងគំនូរ និងរូបព្រះគណេសឆ្លាក់នៅលើថ្មគោលប្រាសាទព្រះគោ (ភ្នំគូលែន)[២] ដែលទំនងជាសិល្បៈខ្មែរនៅស.វ.ទី១១។ ព្រះគណេស គឺជាបុត្ររបស់ព្រះឥសូរ និងព្រះនាងបរ្វតី ដែលមានខ្លួនជាមនុស្សមានពោះកំប៉ោង និងព្រះសិរជាសត្វដំរី ហើយនៅក្នុងព្រហ្មញ្ញសាសនាព្រះគណេស គេចាត់ទុកថាជាទេពនៃបញ្ញា ចំណេះដឹង និងកំចាត់ឧបសគ្គឬអាចដាក់ឧបសគ្គផង។[៣] ការដែលអ្នកស្រុកហៅឈ្មោះលាននេះថា "តាត្រចៀកធំ" ឬ "តាត្រចៀកវែង" ទំនងគេសំដៅទៅលើរូបព្រះគណេសដែលមានត្រចៀកធំឬវែងនេះឯង ព្រោះព្រះគណេសមានព្រះសិរជាសត្វដំរី ម្ល៉ោះហើយត្រចៀកសត្វដំរី គឺធំនិងវែងដូច្នេះឯង។ ការហៅដោយភ្ជាប់ពាក្យ "តា" ពីមុខ ដោយសារអ្នកស្រុកបានចាត់ទុកទេពព្រហ្មញ្ញសាសនានេះជាអ្នកតាប្រចាំភូមិទៅ

---

[១] Boulbet & Dagens 1973: 26.

[២] Boulbet & Dagens 1973: 26, 27, 49; 28-29.

[៣] Roveda 2005: 174-177; Dimmit & Buitenen 1978: 179-185.

ហើយ។ ដ្បិត ជាទូទៅព្រហ្មញ្ញសាសនាតែងដើរទន្ទឹមគ្នាជាមួយជំនឿជីវចល (ជំនឿដើម) ដោយចុះសម្រុងគ្នាបំផុត ពោល គឺពុំមានទោមនស្សអ្វីឡើយ។ សព្វថ្ងៃ ទួលអ្នកតាត្រចៀកធំ សឹងតែបាត់រូបរាងដើមហើយ តែយើងអាចនៅមើលដឹងថា ទួលនេះជាលានមួយដែលរៀបពីថ្មបាយក្រៀម។

រូបភាពទី២ ទំនងជារូបចម្លាក់ក្បាលសត្វមករ (ស្រដៀងក្បាលរាហូ ឬសត្វតោ) ដែលគេឆ្លាក់ជាក្បាលទបង្ហូរទឹក រកឃើញនៅទួលមួយដែលអ្នកស្រុកហៅថា "**ទួលច្រមុះធំ**" ស្ថិតនៅក្នុងភូមិកាំងតេដោ ឃុំថាឡាបរិវ៉ាត់ ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង។ ចម្លាក់សត្វមករនេះមានបណ្ដោយ ៥២ស.ម. កម្រាស់ ៣៩ស.ម. និងកម្ពស់ ៣៩ស.ម. ដែលសព្វថ្ងៃរក្សាទុកនៅឃ្លាំងមន្ទីរវប្បធម៌និងវិចិត្រសិល្បៈខេត្តស្ទឹងត្រែង និងជាសិល្បៈខ្មែរនៅស.វ.ទី៧ (រូបលេខ២)។ មករ គឺជាសត្វទេវកថាមួយប្រភេទដែលផ្សំឡើងពីសត្វលើដីនិងសត្វក្នុងទឹកជាច្រើន ជាទូទៅមានប្រមោយដូចដំរី (ជួនកាលក៏មិនមាន) ផ្នែកខាងក្រោមដូចកន្ទុយត្រី ខ្លួនដូចជាក្រពើឬបក្សី ហើយជារឿយៗមានក្បាលជាសត្វចម្លែក។[៤] នៅសម័យវេទ មករជាយានជំនិះរបស់ព្រះវារុណ ហើយក្រោយពីព្រះវារុណប្ដូរមកជិះសត្វហង្សវិញ មករបានក្លាយជាយានជំនិះរបស់ព្រះនាងគង្គា។[៥] ការហៅទួលនេះថា "ច្រមុះធំ" ក៏មិនខុសពីករណីតាត្រចៀកវែងដែរ ដ្បិតអ្នកស្រុកឃើញរូបចម្លាក់នេះមានច្រមុះធំ ក៏ហៅទីនោះថា "ទួលច្រមុះធំ" តែម្ដង។ ករណីបែបនេះស្រដៀងនឹងការហៅឈ្មោះប្រាសាទមួយនៅតំបន់សំបូរព្រៃគុកដែរ ពោលគឺ "ប្រាសាទក្បាលជ្រូក" (រូបលេខ៣) ដោយហេតុថា គេឃើញទបង្ហូរទឹករូបក្បាលមករមួយនៅជញ្ជាំងខាងក្រៅផ្នែកខាងជើង តែអ្នកស្រុកមិនស្គាល់ថាជាសត្វទេវកថា ក៏ហៅសត្វនោះថា "ក្បាលជ្រូក" (រូបលេខ៤)។

នៅក្នុងសង្គមខ្មែរ ស្ថាននាមដែលកើតចេញពីបរិស្ថានជុំវិញនេះមានច្រើនរាប់មិនអស់។ ពោល គឺគេតែងហៅភ្ជាប់ទីតាំងនោះទៅនឹងអ្វីដែលគេបានឃើញជាក់ស្ដែង ហើយយើងសង្កេតឃើញថាឈ្មោះរុក្ខជាតិគេនិយមខ្លាំងជាងគេ (ឧទាហរណ៍៖ ទួលបេង, ទួលស្រឡៅ, ទួលចារ..)។[៦] ចំណែក ការហៅភ្ជាប់ជាមួយរូបចម្លាក់បែបនេះក៏ឃើញមានច្រើនដែរ ឧទាហរណ៍៖ អ្នកតាក្បាលប្រាំបី (ទេពទាំងប្រាំបីឆ្លាក់សងខាងនៅថ្មគោលចំនួនបួន), អ្នកតាដៃបួន (គេឃើញរូបព្រះវិស្ណុ)..។ អ្វីដែលគួរកត់សម្គាល់នោះគឺ នៅសម័យបុរាណការយកពាក្យ "ច្រមុះ" ប្រើប្រាស់ជាឈ្មោះស្ថាននាមនោះក៏យើងឃើញមានដែរ ឧទាហរណ៍៖ សិលាចារឹកវត្តជើងឯក (K.៤១៦) មានស្ថាននាម

---

[៤] Ananda Coomaraswarmy., K., 1980: 55; Marchal, 1951: 38; Roveda, 2003: 76.

[៥] Sen, 1972: 34; Murthy, 1985; Dwight Whitney, 1971: 623-624.

[៦] សូមអាន កំ វណ្ណារ៉ា ២០២០ "កម្ពុជស្ថាននាមសម័យអង្គរ ស.វ.ទី៩-១៤"។

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

*មួយឈ្មោះថា "**ចុងមុហ**" (ចុងច្រមុះ)[៧], សិលាចារឹកភ្នំដា (K.៨៣០) មានដីមួយកន្លែងឈ្មោះ "**ភូមិមុហថ្នល**" (ភូមិច្រមុះថ្នល់)។[៨]*

*ជារួមមក ស្ថាននាមទាំងពីរដែលបានរៀបរាប់ខាងលើ គឺជាប់ទាក់ទងនឹងបរិស្ថានដែលស្ថិតនៅទីតាំងនោះ ពោល គឺអ្នកស្រុកឃើញព្រះគណេសមានត្រចៀកធំឬវែង គេអាចពុំស្គាល់ថាជាទេពក៏ហៅរូបនោះថា "តាត្រចៀកធំ" ឬ "តាត្រចៀកវែង"។ ចំណែក ករណីមួយទៀតអ្នកស្រុកមិនបានចងចាំតគ្នាថាទួលប្រាសាទដើមអ្វី ក៏ប្រទះភ្នែកឃើញរូបចម្លាក់ក្បាលមករមានច្រមុះធំ គេក៏ហៅទីនោះថា "ទួលច្រមុះធំ" តែម្តង។*

## ឯកសារយោង


### *កំ វណ្ណារ៉ា*

២០២០, "*កម្ពុជស្ថាននាមសម័យអង្គរ ស.វ.ទី៩-១៤*", ភ្នំពេញ

**Annanda, Coomarswarmy K.,**
1980, *Yaksa,* New Delhi

**Boulbet, Jean & Dagens, Bruno**
1973, "Les sites archéologiques de la région du Bhnaṃ Gūlen (Phnom Kulen)", *Journal of Art Asiatique*, Vol 27, Paris

**Coedès, George**
- 1950, *Inscription du Cambodge*, Vol II, Hanoi
- 1953, *Inscription du Cambodge*, Vol V, Hanoi

**Dilliam Dwight, Whitney**
1971, *Atharva – Veda – Samhita,* New Delhi

**Dimmit, Cornelia & Buitenen, J.A.B**
1978, Classical Hindu Mythology, USA

**Marchal, Henri**
1951, *Le décor et la sculpture Khmer,* Paris

**Murthy, Krishna**
1985, *Mythical animals in Indian arts*, New Delhi
angkorienne, *Art Asiatiques*, Tome XIV.

**Roveda, Victorio**
- 2003, *The Khmer mythology*, Bangkok
- 2005, "*Image of the gods*", Bangkok

**Saveros Pou**
1992, *Dictionnaire Vieux Khmer-Français-Englais*, Paris

**Sen, Asia**
1972, *Animal motif in ancient Indian arts*, Culcutta


---

[៧] Coedès 1950: 121; Saveros Pou 1992: 376.

[៨] Coedès 1953: 278; Saveros Pou 1992: 376.



រូបលេខ១៖ ព្រះគណេសព្រះហស្តប្រាំបី អ្នកស្រុកហៅ "តាត្រចៀកធំ" (រូបថត៖ ឡុន ណាក់)



រូបលេខ២៖ ទបង្ហូរទឹករូបក្បាលមករ (?) អ្នកស្រុកហៅ "ច្រមុះធំ"

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ២៣៖ ប្រាសាទក្បាលជ្រូក (N20-1) តំបន់ប្រាសាទសំបូរព្រៃគុក ស.វ.ទី៧



រូបលេខ២៤៖ ទបង្ហូរទឹករូបក្បាលមករ អ្នកស្រុកហៅ "ក្បាលជ្រូក"

អត្ថបទដោយ៖ ម៉ង់ វ៉ាលី